**Ministry of Agriculture Forestry and Fisheries**

**Climate-Friendly Agribusiness Value Chains Sector Project (CFAV)**
**ADB Loan No. 3661-CAM (COL), 8346-CAM (EF) and Grant No. 0579 (EF)**
**គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន**

# ព្រាងរបាយការណ៍សង្ខេបសិក្ខាសាលា ស្តីពី បុរេបេសកកម្ម នៃការចាប់ផ្តើមគម្រោងខ្សែច្រវ៉ាក់ផលិតកម្ម ដោយភាតរៈបរិស្ថាន

Draft summary workshop report on Pre-Inception Mission of
Climate-Friendly Agribusiness Value Chains Sector Project ( CFAVC )






# មាតិការបាយការណ៍សង្ខេបសិក្ខាសាលាស្តីពីបុរេបេសកកម្មនៃការចាប់ផ្តើមគម្រោង

Content draft summary workshop report on Pre-Inception Mission of CFAVC Project


I. លំនាំដើម និងសេចក្តីសង្ខេប(Introduction and Executive summary) ..................................3

II. សកម្មភាព និងលទ្ធផលដែលទទួលបានពីសក្ខាសាលារួមមាន ..................................4

1.1 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលា ថ្ងៃទីមួយមាន៖ ..................................4

1.2 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលាថ្ងៃទីពីរមាន៖ ..................................8

1.3 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលា ថ្ងៃទីបីមាន៖ ..................................10

III. សេចក្តីសន្និដ្ឋាន ..................................10

## I. លំនាំដើម និងសេចក្តីសង្ខេប( Introduction and Executive summary )

ក្នុងកំឡុងពេល ៣ថ្ងៃ (៣ដល់៥ កក្កដា ឆ្នាំ២០១៩) សិក្ខាសាលាស្តីពី បុរេបេសកកម្មនៃការចាប់ផ្តើមគម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន បានដំណើរការ និងប្រព្រឹត្តទៅនៅទីស្តីការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួមមកពី ក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទដែលជាអ្នកអនុវត្តគម្រោងទាំងថ្នាក់ជាតិ (PMU IAs) និងខេត្ត (PPIU) រួមទាំងក្រុមបេសកកម្ម ដៃគូរអភិវឌ្ឍន៍ Asian Development Bank (ADB) ដែលមានអ្នកចូលរួមសរុប ៦០នាក់ ក្នុងនោះមានស្រ្តី ១០នាក់ (មានជូនភ្ជាប់លម្អិតបញ្ជីវត្តមានអ្នកចូលរួមក្នុង **ឧបសម្ព័ន្ធទី១**)។

គោលបំណងសិក្ខាសាលារយៈពេល៣ថ្ងៃនេះគឺមានគោលបំណងបង្កើនសហប្រតិបត្តិការខ្ពស់ និងផ្សារភ្ជាប់នូវទំនាក់ទំនងអោយកាន់តែជិតស្និទ្ធល្អប្រសើរថែមទៀត ជាមួយដៃគូអភិវឌ្ឍន៍ និងជំរុញការពង្រឹងសមត្ថភាពដល់មន្រ្តីដែលជាអ្នកអនុវត្តគម្រោងដើម្បីរៀបចំកិច្ចដំណើរការ អនុវត្តសកម្មភាពបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

សកម្មភាពសិក្ខាសាលារយៈពេលពេញ ៣ថ្ងៃនេះមាន៖

- ***សកម្មភាពសិក្ខាសាលា ថ្ងៃទីមួយមាន៖***
  1. មតិស្វាគមន៍ និងបើកសិក្ខាសាលាដោយ **លោកបណ្ឌិត សំ ឆោមសង្ហា** នាយកគម្រោង CFACV (MAFF), ឯកឧត្តម Chandarong, CFACV (MRD), ឯកឧត្តម Chann Sinath, CFACV (MoWRAM) និង Mr. Srinivasan Ancha, Project Officer ADB
  2. បទបង្ហាញទី 1: ទិដ្ឋភាពទូទៅនៃគម្រោង និងគោលបំណងនៃបេសកកម្មដោយ Mr. Srinivasan Ancha, Project Officer ADB។
  3. បទបង្ហាញទី 2: បទបង្ហាញវឌ្ឍនភាពអនុវត្តគម្រោង និងបញ្ហានានាដែលមានកន្លងមក និងរៀបចំការរៀបចំអនុវត្តគម្រោងបន្តដោយ **លោក ងិន កុសល** អ្នកសម្របសម្រួលគម្រោងជាតិ (National Project Coordinator, NPMO)
  4. បទបង្ហាញទី ៣: បទបង្ហាញតម្រូវការរបាយការណ៍គម្រោងដោយ Mr. Leonard Leung Economist, ADB
  5. បទបង្ហាញទី ៤: បទបង្ហាញ ការការពារសុវត្ថិភាពសង្គម និងបរិស្ថាន (Social and Environmental Safeguards) ដោយ Ms. Rangina Nazrieva – Social and Mr. Sour Sethy – Environment, ADB.
- ***សកម្មភាពសិក្ខាសាលា ថ្ងៃទីពីរ មាន៖***
  1. បទបង្ហាញទី ៥: បទបង្ហាញ ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management) ដោយ Ms. Delany P. Miram, អ្នកជំនាញ វិភាគ និងគ្រប់គ្រងហិរញ្ញវត្ថុ, ADB.
- ***សកម្មភាពសិក្ខាសាលា ថ្ងៃទីបីមាន៖***
  1. បទបង្ហាញទី ៦: បទបង្ហាញ ផែនការសកម្មភាពយេនឌ័រ (Gender Action Plan) ដោយ Ms. Pisey, Gender Officer, ADB
  2. បទបង្ហាញទី ៧: បទបង្ហាញពីបញ្ហាលទ្ធកម្ម (Procurement issues) ដោយ Mr. Vijay Akasam and Mr. Sokunthea Sok Officer, ADB

3. ពិភាក្សារួមគ្នា និងពិធីបិទសិក្ខាសាលា

ឆ្លងតាមរយៈពេលសិក្ខាសាលាស្ដីពីបុរេបេសកកម្មនៃការចាប់ផ្ដើមគម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន ៣ថ្ងៃនេះចាប់ពីថ្ងៃទី៣ ដល់៥ កក្កដា ឆ្នាំ២០១៩ (មានជូនភ្ជាប់ពង្រៀងកម្មវិធីសិក្ខាសាលា ៣ថ្ងៃ ស្ដីពីបុរេបេសកកម្មនៃគម្រោងCFAVC **ឧបសម្ព័ន្ធទី២**) បានដំណើរការ និងប្រព្រឹត្តទៅដោយរលូនដូចការគ្រោងទុក និងមានការពិភាក្សាស្វែងយល់ពីគ្នាទៅវិញទៅមកយ៉ាងផុលផុសរវាងស្ថាប័ន និងស្ថាប័ន តួនាទីភារកិច្ច ការគ្រប់គ្រង និងការអនុវត្តគម្រោង នៅកំរិតថ្នាក់ជាតិ និងខេត្តព្រមទាំងអង្គភាពពាក់ព័ន្ធនានា រួមទាំងមានការចូលរួមពីដៃគូរអភិវឌ្ឍន៍គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន CFAVC ផងដែរ។

## II. សកម្មភាព និងលទ្ធផលដែលទទួលបានពីសក្ខាសាលារួមមាន

### 1.1 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលា ថ្ងៃទីមួយមានៈ

- ជាកិច្ចចាប់ផ្ដើមអង្គសិក្ខាសាលាមានមតិស្វាគមន៍ និងបើកសិក្ខាសាលាដោយៈ

1. **លោកបណ្ឌិត សំ ឆោមសង្ហា** នាយកគម្រោង CFACV (MAFF), *មានជូនភ្ជាប់លម្អិត* ***ឧបសម្ព័ន្ធទី៣***



2. ឯកឧត្តម Chandarong, CFACV (MRD), *មានជូនភ្ជាប់លម្អិត* ***ឧបសម្ព័ន្ធទី៤***



3. ឯកឧត្តម Chann Sinath, CFACV (MoWRAM) និង



4. Mr. Srinivasan Ancha, Project Officer ADB



- **បទបង្ហាញទី 1**: ទិដ្ឋភាពទូទៅនៃគម្រោង និងគោលបំណងនៃបេសកកម្ម ដោយ Mr. Srinivasan Ancha, Project Officer ADB។ លោកបានធ្វើបទបង្ហាញអំពីការវាយតម្លៃស្ទាបស្ទង់ពីស្ថានភាពទូទៅដែលយើងបានអនុវត្តគម្រោងកន្លងមកទៅលើ៖
    - ស្ថានភាពនៃការរៀបចំបុគ្គលិកគម្រោង
    - ស្ថានភាពលទ្ធកម្មការផ្គត់ផ្គង់សេវាទីប្រឹក្សាការងារ និងទំនិញ
    - ផ្តល់ការណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ
    - ផ្តល់ការណែនាំស្តីពីការការពារសុវត្ថិភាពសង្គម និងបរិស្ថាន
    - ផ្តល់ការណែនាំស្តីពីជំហ៊ាននានាក្នុងការពន្លឿនលទ្ធកម្មជ្រើសរើសអ្នកពិគ្រោះយោបល់ការងារ និងទំនិញ
    - ការពិភាក្សាអំពីតួនាទីណីមួយៗច្បាស់លាស់តាមឋានានុក្រមរបស់គម្រោង
    - ទីតាំង និងប្រភេទផលិតកម្មដំណាំរបស់គម្រោង
    - ផលប៉ះពាល់ និងលទ្ធផលរំពឹងទុករបស់គម្រោង
    - សង្ខេបផែនការផ្តល់ហិរញ្ញប្បទានរបស់គម្រោង
    - ការរៀបចំសំខាន់ៗនៃការអនុវត្តគម្រោង រួមទាំងការរៀបចំលំហូរថវិការរបស់គម្រោង
    - សកម្មភាពគន្លឹះដែលគម្រោងបានអនុវត្តមក និងហេតុផលសំខាន់ៗសម្រាប់ការដែលបណ្តាលអោយមានការយឺតយ៉ាវអនុវត្តគម្រោង
- Mr. Srinivasan Ancha, **លោកបានធ្វើបទបង្ហាញផងដែរអំពី៖**
    - វិធីសាស្ត្រគម្រោង
    - លក្ខណៈវិនិច្ឆ័យការជ្រើសរើសសម្រាប់អនុគម្រោងលើប្រព័ន្ធធារាសាស្ត្រ
    - លក្ខណៈវិនិច្ឆ័យសម្រាប់ទីតាំងសាងសង់ស្រះទឹក
    - លក្ខណៈវិនិច្ឆ័យសម្រាប់កន្លែងធ្វើប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក
    - លក្ខណៈវិនិច្ឆ័យសម្រាប់សហគមន៍កសិកម្ម
    - លក្ខណៈវិនិច្ឆ័យសម្រាប់ផ្លូវលំពីកសិដ្ឋាន ដើម្បីភ្ជាប់សហគមន៍កសិកម្ម និងទីផ្សារ
    - លក្ខណៈវិនិច្ឆ័យសម្រាប់ការគាំទ្រឡជីវឧស្ម័ន
    - គោលការណ៍ណែនាំការពារសុវត្ថិភាពសំខាន់ៗរបស់គម្រោង
    - ការបញ្ជ្រាប និងសកម្មភាពយេនឌ័រសំខាន់ៗរបស់គម្រោង

  *សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី៥***

- **បទបង្ហាញទី 2**: បទបង្ហាញស្តីពីវឌ្ឍនភាពអនុវត្តគម្រោង និងបញ្ហានានាដែលមានកន្លងមក និងការរៀបចំអនុវត្តគម្រោងបន្តដោយ **លោក ងិន កុសល** អ្នកសម្របសម្រួលគម្រោងជាតិ (National Project Coordinator, NPMO)។



**លោក ងិន កុសល** បានបទបង្ហាញស្តីពីវឌ្ឍនភាពអនុវត្តគម្រោង CFACV ដែលជារួមមាន៖

- ព័ត៌មានសង្ខេប និងសមាសភាគសំខាន់ៗនៃគម្រោង
- ផែនទីទីតាំងខេត្តគោលដៅ និងប្រភេទផលិតកម្មដំណាំ
- ប្រភព និងការបែងចែកថការបស់គម្រោង
- រចនាសម្ព័ន្ធអង្គភាពគ្រប់គ្រងគម្រោង
- ដំណើរការ និងលទ្ធផលលទ្ធកម្មជ្រើសរើសសេវាកម្មការងារ និងទិញទំនិញ
- បង្ហាញសូចនាលទ្ធផលរំពឹងទុកសំខាន់ៗនៃគម្រោង
- បង្ហាញពីវឌ្ឍនភាព និងបញ្ហាប្រឈមការអនុវត្តគម្រោងកន្លងមក

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង **ឧបសម្ព័ន្ធទី៦***

- **បទបង្ហាញទី ៣**: បទបង្ហាញពីតម្រូវការ របាយការណ៍ និងការតាមដានត្រួតពិនិត្យគម្រោង ដោយ Mr. Leonard Leung Economist, ADB។



**លោក** Mr. Leonard Leung បានធ្វើបង្ហាញស្តីពីតម្រូវការទាំងនេះដែលជារួមមាន៖

- គ្រោងក្របខ័ណ្ឌការងារ និងការតាមដានត្រួតពិនិត្យការអនុវត្តគម្រោង(Design and Monitoring Framework (DMF))។

- ○ ទម្រង់វាយតំលៃលើការអនុវត្តន៍គម្រោង (Project Performance Rating)
- ○ ទម្រង់បែបបទការរាយការណ៍ (ប្រព័ន្ធតាមដានការអនុវត្តគម្រោង ការការពារសុវត្ថិភាពសង្គម និងយេនឌ័រ)

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង **ឧបសម្ព័ន្ធទី៧***

## 1.2 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលាថ្ងៃទីពីរមានៈ

បទបង្ហាញទី ៥: ស្តីពីគារការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management) បទបង្ហាញដោយ Ms. Delany P. Miram, អ្នកជំនាញ វិភាគ និងគ្រប់គ្រងហិរញ្ញវត្ថុ, ADB។



Ms. Delany P. Miram បានបង្ហាញ៤ផ្នែកសំខាន់ៗ ទាក់ទងទៅនឹងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ៖

1. បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងវិធានការដើម្បីពង្រឹងគម្រោងលើការគ្រប់គ្រងហិរញ្ញវត្ថុ
2. បទបង្ហាញពីតម្រូវការអោយមាន របាយការណ៍ហិរញ្ញវត្ថុរបស់ ADB
3. បទបង្ហាញពី តម្រូវការអោយមានសវនកម្មរបស់ ADB
4. បទបង្ហាញពីការកំណត់ផែនការសកម្មភាពជាមួយនឹងពេលវេលាដែលត្រូវធ្វើ និងវិធានការកាត់បន្ថយហានិភ័យ ។

- សម្រាប់បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងវិធានការដើម្បីពង្រឹងគម្រោងលើការគ្រប់គ្រងហិរញ្ញវត្ថុជារួមមាន៖
    - ○ ឯកសារយោងស្តីពីគម្រោង និងឯកសារយោងហិរញ្ញវត្ថុ
    - ○ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុ
    - ○ ការប៉ាន់ប្រមាណការចំណាយរបស់គម្រោង និងថវិកា
    - ○ ការលំហូរថវិកា និងការទូទាត់
    - ○ ការគ្រប់គ្រងសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរបស់គម្រោង
    - ○ ការគ្រប់គ្រងផ្ទៃក្នុង

- ធាតុសំខាន់នៃការគ្រប់គ្រងផ្ទៃក្នុង
- ការត្រួតពិនិត្យផ្ទៃក្នុងហិរញ្ញវត្ថុទូទៅ
- គម្រោងហិរញ្ញវត្ថុ គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ
- សវនកម្មផ្ទៃក្នុង
- សវនកម្មពីខាងក្រៅ

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី៨***

- សម្រាប់បទបង្ហាញពីតម្រូវការអោយមាន របាយការណ៍ហិរញ្ញវត្ថុរបស់ ADB ជារួមមាន៖
  - គម្រោងហិរញ្ញវត្ថុ គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ
  - ការថែរក្សាកំណត់ត្រាគម្រោង និងគណនី
  - គំរូរបាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី៩***

- សម្រាប់បទបង្ហាញពីតម្រូវការអោយមានសវនកម្មរបស់ ADB ជារួមមាន៖
  - គោលការណ៍ណែនាំតម្រូវការសវនកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី
  - របាយការណ៍សវនកម្មគម្រោងគំរូ

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី ១០***

- សម្រាប់បទបង្ហាញពីការកំណត់ផែនការសកម្មភាពជាមួយនឹងពេលវេលាដែលត្រូវអនុវត្ត និងវិធានការកាត់បន្ថយហានិភ័យជារួមមាន៖
  - វិធានបង្កាការពារហានិភ័យនៃការគ្រប់គ្រងហិរញ្ញវត្ថុ
  - ផែនការសកម្មភាពដែលកំណត់ពេលវេលាដើម្បីដោះស្រាយហានិភ័យនៃការគ្រប់គ្រងហិរញ្ញវត្ថុ
  - មានការចែកពិភាក្សាជាក្រុមជាបីក្រុម (ក្រុម MAFF ក្រុម MOWRAM និងក្រុមMRD) ដើម្បីពិភាក្សាស្ទាបស្ទង់សមត្ថភាពបឋម ទៅសំនួរមួយចំនួនដូចខាងក្រោមទាក់ទងទៅនឹង៖
    - សមត្ថភាពរបស់បុគ្គលិកទាក់ទងទៅនឹងការគ្រប់គ្រងហិរញ្ញវត្ថុ
    - ផែនការថវិកា និងការពិនិត្យថវិកា
    - ការត្រួតពិនិត្យផ្ទៃក្នុង និងរបៀបដែលនឹងត្រូវអនុវត្ត
    - ការទទួលខុសត្រូវ (តើនរណា នឹងធ្វើអ្វី?)
    - លំហូរមូលនិធិ និងការទូទាត់
    - របាយការណ៍ហិរញ្ញវត្ថុ
    - តើអ្នកត្រូវការអ្វីខ្លះ?
    - ភាពញឹកញាប់នៃការពិនិត្យឯកសារ និងអ្នកដែលនឹងពិនិត្យឡើងវិញ
    - រចនាសម្ព័ន្ធរបាយការណ៍ (តើអ្នកនឹងរាយការណ៍ នរណា?)

- បញ្ជីទ្រព្យសម្បត្តិ និងចុះកិច្ចសន្យា

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី ១១***

## 1.3 សកម្មភាព និងលទ្ធផលដែលទទួលបានពីសិក្ខាសាលា ថ្ងៃទីបីមាន៖

ក្នុងថ្ងៃទីបីនេះកម្មវិធីពេលព្រឹកបែងចែកជាពីរក្រុម ដោយក្រុមទីមួយជាក្រុមពិភាក្សាគ្នាលើដំណើការគ្រប់គ្រងថវិការ។ និងក្រុមទីពីរពិភាក្សាពីការការពាសុវត្ថិភាពសង្គម និងយែនឌ័រ ដែលជាផ្នែកមួយសំខាន់តម្រូវអោយមាននៅក្នុងការប្រើប្រាស់ធិមូលនិធិបៃតង (CFG) ក្នុងការអនុវត្តគម្រោង CFAVC។ យែនឌ័រ គួរតែគិតគូរបញ្ជ្រាបផងដែរតាំងពីការចាប់ផ្តើមអនុវត្តគម្រោង។ ហើយកម្មវិធីបន្ទាប់ក៍មានបទបង្ហាញជាក្រុមរួម Mr. Sokunthea Sok and Mr. Vijay Akasam ស្តីពីដំណើរការលទ្ធកម្មជាពិសេស ដំណើការលទ្ធកម្មថ្នាក់ជាតិ National Competitive Bidding Documents (NCB)។ រួមមានតាំងពីជំហ៊ាន ការផ្សព្វផ្សាយព័តមានលទ្ធកម្ម (NCB) ការប្រើប្រាស់ឯកសារបែបបទលទ្ធកម្ម រហូតដល់កិច្ចសន្យា (Contract agreement)។

*សម្រាប់សេចក្តីលម្អិតមានជូនភ្ជាប់បទបង្ហាញក្នុង* ***ឧបសម្ព័ន្ធទី ១២***

# III. សេចក្តីសន្និដ្ឋាន

ឆ្លងតាមសិក្ខាសាលាស្តីពីបុរេបេសកកម្មនៃការចាប់ផ្តើមគម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថានរយៈពេល ៣ថ្ងៃ (៣ដល់៥ កក្កដា ឆ្នាំ២០១៩) កន្លងមកបានដំណើរការ និងប្រព្រឹត្តទៅនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលមានអ្នកចូលរួមមកពីក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទដែលជាអ្នកអនុវត្តគម្រោងទាំងថ្នាក់ជាតិ (PMU IAs) និងខេត្ត (PPIU) រួមទាំងក្រុមបេសកកម្ម ដៃគូរអភិវឌ្ឍន៍ Asian Development Bank (ADB) បានបញ្ចប់ដូចការគ្រោងទុកប្រកបដោយជោគជ័យ និងការមានចូលរួមចែករំលែកពត៌មានសំខាន់ៗស្តីពីការត្រៀម អនុវត្តន៍គម្រោងយ៉ាងផុលផុសពីគ្រប់ភាគីអ្នកចូលរួមដែលពាក់ព័ន្ធអនុវត្តគម្រោងសំខាន់ៗ។ ដែលជាពិសេសអ្នកចូលរួមទាំងអស់បានទទួលនូវព៌តមានលម្អិតសំខាន់ៗ ស្តីពីគម្រោង គោលការណែនាំស្តីពីការគ្រប់គ្រង និងដំណើរការអនុវត្តគម្រោង តម្រូវការបន្ថែមនៃគណនេយ្យកររបស់អង្គភាពភ្នាក់ងារអនុវត្តគម្រោង និង ការរៀបចំឱ្យមានជនបង្គោលយិនឌ័រដោយដាច់ពីមន្ត្រីការពាសុវត្ថិភាពសង្គម។

